ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ២១១
ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩
**សាលដីកា**
លេខ ៤៨ VII
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ប្រធាន
២.លោក [redacted] ចៅក្រម
៣.លោក [redacted] ចៅក្រម
៤.លោក [redacted] ចៅក្រម
៥.លោក [redacted] ចៅក្រម

**ចៅក្រមរបាយការណ៍**

លោកស្រី [redacted]

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted]

**តំណាងមហាអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៤៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ស្រីពេជ្រ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៧ " ក្រVI ច " ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ បំរើការងារនៅហាងខាត់អូខ យូស្តារ ទីកន្លែងកំណើត [redacted]

Scanned with CamScanner

[redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" មានកូន ០១ នាក់ ។ ប្រវត្តិទោសពីមុនគ្មាន (អ្នកប្ដឹងសាទុក្ខ)

- លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិ

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ បទល្មើសដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.អំពីអង្គហេតុ:

កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ សមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀន រាជធានីភ្នំពេញ បានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយអនុវត្តវិធានញុះញង់ឱ្យលក់ដោយខុសច្បាប់ ហើយសមត្ថកិច្ចក៏បានទូរស័ព្ទទិញគ្រឿងញៀនពីមនុស្សប្រុសម្នាក់ ហើយចាំទទួលយកគ្រឿងញៀននៅទីតាំងកំណត់មួយក្នុងភូមិត្រពាំងឈូក ហើយសមត្ថកិច្ចក៏ដាក់កម្លាំងចាំឃ្លាំមើល ពេលនោះមានមនុស្សស្រីម្នាក់ដើរមកកាន់ចំណុចកើតហេតុ សមត្ថកិច្ចមានការសង្ស័យ ក៏បានឆែកឆេរកាបូបស្រីម្នាក់នោះ រកឃើញកញ្ចប់ដែលសង្ស័យជាគ្រឿងញៀន ហើយសមត្ថកិច្ចក៏បាននាំខ្លួនស្ត្រីម្នាក់នោះមកសាកសួរទើបដឹងថាក្រុមជនល្មើសឈ្មោះ [redacted] ស្រីពេជ្រ ហៅ ពេជ្រ , ឈ្មោះ ភាព ភេទប្រុស និង ក្មេងប្រុសម្នាក់ទៀតអញ្ញាតជន ជាក្រុមរកស៊ីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយឈ្មោះ ភាព បានប្រើក្មេង ប្រុសម្នាក់ ដែលជាអញ្ញាតជនឲ្យយកគ្រឿងញៀនមកប្រគល់ឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ នៅមុខមន្ទីរពេទ្យលោកសង្ឃ ដើម្បីឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ យកគ្រឿងញៀននោះទៅប្រគល់ឲ្យគេបន្តទៀតនៅភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលដែលជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ ទៅដល់ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៧៤ ក្រ៦ "ដ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១.សម្រេចផ្តន្ទាទោសៈ

ក-ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាម មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុតាងមានដូចក្នុងកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជ ធានីភ្នំពេញមាន ៖

-ស្រោមសំបុត្រពណ៌ស បិតស្កុតជិត សសេរដាក់ថា ៖ ក្រាមពណ៌សថ្លា ប្រភេទមេតំហ្វេតាមីនទម្ងន់ ៩២,២៣ក្រាម (កៅសិបពីកៀសម្ភៃបីក្រាម) និងសំបកថង់ផ្លាស្ទិកចំនួន០១ ។

Scanned with CamScanner

-សម្រេចរឹបអូស តាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ទូរស័ព្ទដៃម៉ាកណូគា ចុចពិល ពណ៌ខៀវចំនួន ០១គ្រឿង ។ សម្រេចរឹបអូសប្រគល់ឲ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ស្រីពេជ្រ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៧៤ ក្រ៦ "ដ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣៧ " ក្រVI ច " ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ស្រីពេជ្រ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៧៤ ក្រ៦ "ដ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែលទាំងមូល ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១៤៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ស្រីពេជ្រ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៣៧ " ក្រVI ច " ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

**២.នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខលេខ ១៤៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដូច្នេះតំណាងមហាអយ្យការស្នើសុំឱ្យតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានដដែល ។

-ជនជាប់ចោទ [redacted] ស្រីពេជ្រ ឆ្លើយថា ៖ ខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ក្នុងគោលបំណងបន្ធូរបន្ថយទោស ព្រោះខ្លួនមិនបានជួញដូរគ្រឿងញៀននោះទេ គេប្រើខ្លួនឱ្យយកទៅតែប៉ុណ្ណោះ ហើយខ្លួនក៏បានប្រើប្រាស់គ្រឿងញៀនផងដែរ ។ ខ្លួនសំណូមពរឱ្យតុលាការធ្វើការបន្ធូរបន្ថយទោស ដើម្បីឱ្យខ្លួនបានទៅធ្វើការចិញ្ចឹមម្តាយជរា និងកូនប្រុសរបស់ខ្លួននៅផ្ទះ ។

Scanned with CamScanner

-លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនមានគោលបំណងគ្រាន់តែដោះដូរគ្រឿងញៀន ដើម្បីយកមកប្រើប្រាស់តែប៉ុណ្ណោះ ។ ដោយសារតែកូនក្តីខ្លួនជានារីខាវ៉ាអូខេ ត្រូវធ្វើការតាំងពីល្ងាចរហូតដល់ភ្លឺ ហើយមិនអាចទ្រាំនឹងការអត់ងងុយបាន ទើបធ្វើឱ្យកូនក្តីខ្លួនសម្រេចចិត្តប្រើប្រាស់គ្រឿងញៀន ដើម្បីមានពេលវេលាក្នុងការរកប្រាក់កម្រៃ ចិញ្ចឹមម្តាយ និងកូនប្រុសរបស់ខ្លួន ។ កូនក្តីខ្លួនក៏បានសារភាពរាល់កំហុសដែលខ្លួនបានប្រព្រឹត្ត ហើយអំពើរបស់កូនក្តីខ្លួនប្រព្រឹត្តនេះក៏ជាលើកទីមួយផងដែរ ។ យោងតាមអង្គច្បាប់ មាត្រា ៤០ កថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺទណ្ឌកម្មបានកំណត់រយៈពេលពី ៥ ឆ្នាំ រហូតដល់ ១០ ឆ្នាំ បើទោះបីជាសាលាឧទ្ធរណ៍បានធ្វើការបន្ធូរបន្ថយទោសឱ្យនៅត្រឹម ៦ ឆ្នាំ ក៏ដោយ ឃើញថាកូនក្តីខ្លួនដែលបានយកគ្រឿងញៀនទៅឱ្យនោះ មិនបានទទួលផលប្រយោជន៍ជាថវិកានោះទេ ហើយការដោះដូរជាគ្រឿងញៀនដើម្បីយកទៅប្រើប្រាស់ ក៏មិនបានទទួលផងដែរ ។ ខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យទៅលើផលប្រយោជន៍ ដែលកូនក្តីខ្លួនទទួលបាន ហើយប្រៀបធៀបទៅនឹងការសម្រេចរបស់តុលាការ ដែលធ្វើការដាក់ទណ្ឌកម្មកូនក្តីខ្លួន ៦ ឆ្នាំ នោះ គឺកូនក្តីខ្លួនមិនបានទទួលផលប្រយោជន៍អ្វីទាល់តែសោះ ក្រៅពីទណ្ឌកម្ម ។ ខ្លួនសំណូមពរឱ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណាអំពីកម្រិតទណ្ឌកម្ម ដាក់ទោសកូនក្តីខ្លួនត្រឹមរយៈពេល ៥ ឆ្នាំ ។

- ក្រោយពីបានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ ចំលើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៤៥ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៩ របស់ជនជាប់ចោទ [redacted] ស្រីពេជ្រ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នៅចំពោះមុខតុលាការកំពលនេះ ជនជាប់ចោទ [redacted] ស្រីពេជ្រ និងមេធាវីបានសុំឱ្យតុលាការកំពូល សម្រេចបន្ធូរបន្ថយទោសរបស់ជនជាប់ចោទមកត្រឹម ៥ ឆ្នាំ ដែលជាអប្បរមានៃទោស ដែលជនជាប់ចោទបានប្រព្រឹត្ត ដោយបានលើកយកមូលហេតុថា ជនជាប់ចោទ ទើបប្រព្រឹត្តបទល្មើសជាលើកទី ១ មានការដោទលូង់បានសហការជាមួយសមត្ថកិច្ច ហើយការប្រព្រឹត្តបទល្មើសនេះ ដើម្បីទទួលបានកម្រៃបន្តិចបន្តួចសម្រាប់ចិញ្ចឹមគ្រួសារក្រីក្រនោះ តុលាការកំពូលពិនិត្យឃើញថា នៅគ្រប់ដំណាក់កាលនៃនីតិវិធី ជនជាប់ចោទបានទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួន ហើយតាមភស្តុតាងដែលសមត្ថកិច្ចបានចាប់យកជាក់ស្តែង បានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្ត បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយការសម្រេចផ្តន្ទាទោសលើជនជាប់ចោទ ៦ ឆ្នាំ ស្ថិតនៅក្នុងកម្រិតនៃទោសស្របច្បាប់ ដែលការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ មិនមានកំហុស

Scanned with CamScanner

នោះទេ ។ ម្យ៉ាងទៀត តាមបញ្ញត្តិនៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលមានសមត្ថកិច្ចពិនិត្យតែលើការអនុវត្តច្បាប់ របស់សាលាឧទ្ធរណ៍តាមរយៈបណ្តឹងសាទុក្ខរបស់ជនជាប់ចោទប៉ុណ្ណោះ តុលាការកំពូល មិនមានសមត្ថកិច្ចធ្វើការសម្រេចអំពីទោសឡើងវិញនោះទេ ដូចមានកំណត់ក្នុងបញ្ញត្តិមាត្រា ៤៤០ និងមាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទមានមូលហេតុមិនត្រូវទៅនឹងមូលហេតុនៃបណ្តឹងសាទុក្ខ ដូចមានកំណត់នៅក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៧ "ក្រVI.ច" ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## សម្រេច

១. **បដិសេធ** បណ្តឹងសាទុក្ខលេខ ១៤៥ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីពេជ្រ ។

២. **តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ៣៧ " ក្រVI ច " ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner